# ១៥_រឿង អាឡេវ

កាលពីព្រេងនាយ មានបុរសម្នាក់ឈ្មោះអ្នកង៉េះប្រពន្ធឈ្មោះនាងង៉ោះមានកូនប្រុសម្នាក់ឈ្មោះអាឡេវ ។ កូននោះលុះធំឡើងអាយុ៧ឆ្នាំជាក្មេងមានប្រាជ្ញាដឹងថាម្តាយឪពុកល្ងង់មិនចេះធ្វើការរកស៊ី ជាអ្នកក្រលំបាក វាក៏និយាយនឹងម្តាយឪពុកវាថា "ម៉ែអើយ! ឪពុកអើយ! ឥឡូវនេះយើងគ្មានរបរធ្វើការរកស៊ីនឹងគេ បានជាយើងក្រ បើដូច្នេះខែវស្សាយើងធ្វើស្រែ ខែប្រាំង យើងទៅធ្វើចំការ ឯខ្ញុំទៅធ្វើស្រែជាមួយនឹងឪឯង បើយើងអត់ស្លាម្លូអង្ករម្ហូបចំណីអ្វី សឹមខ្ញុំមកយកពីផ្ទះនេះទៅស៊ី " ។ អាឡេវនិងឪពុកម្តាយគិតគ្នាព្រមហើយក៏រៀបប្រដាប់ប្រដាឡើងទៅធ្វើស្រែ ។ លុះទៅស្រែយូរអាឡេវនឹកចង់ស៊ីនំ ហើយវាគិតថា "បើដូច្នេះអញនឹងបញ្ឆោតម៉ែឪអញយកនំស៊ី" គិតហើយប្រាប់ឪពុកវាថា "ឪៗខ្ញុំទៅផ្ទះយកស្លាម្លូមកស៊ី " ។ ឪពុកក៏អោយកូនទៅផ្ទះ ។ អាឡេវដើរទៅដល់កណ្តាលផ្លូវបានឃើញវត្តលោកសង្ឃក៏ចូលទៅថ្វាយបង្គំរកលោកកោរសក់អោយ លុះកោររួចហើយក្រាបបង្គំថ្វាយលាលោកទៅលុះទៅដល់ជិតផ្ទះអាឡេវយកសំពត់ទទូរក្បាលហើយធ្វើជាយំចូលទៅក្នុងផ្ទះ ។ ឯម្តាយឃើញកូនយំដូច្នោះក៏សួរទៅថា "ថ្វីក៏កូនយំ ?" ។ អាឡេវធ្វើជាយំខ្លាំងឡើងថែមទៀត ។ ម្តាយឃើញកូនរិតតែយំខ្លាំងឡើងដូច្នោះ ក៏ស្ទុះទៅឱបហើយបើកសំពត់អំពីក្បាលកូនចេញ ឃើញក្បាលកោរសក់រិតតែសង្ស័យ ហើយសួរទៀតថា "ហេតុអ្វីក៏បានជាកោរសក់ហើយយំដូច្នេះ?" ។ អាឡេវប្រាប់ម្តាយថា "ឪគាត់ស្លាប់ទៅហើយ " ។ នាងង៉ោះឮកូនថាដូច្នោះ ក៏គក់ទ្រូងស្រែកទួញយំអាឡោះអាល័យរៀបរាប់ពីកាលចាប់ដៃបានគ្នាជាប្តីប្រពន្ធរៀងរាបដរាបមក ។ អាឡេវឃើញម្តាយយំសង្រេងសង្រៃដូច្នោះក៏អង្វរលួងលោមម្តាយថា "អ្នកម៉ែអើយ! អ្នកកុំយំបើអ្នកចេះតែយំ តើធ្វើដូចម្តេចនឹងបានធ្វើបុណ្យទានបញ្ជូនទៅអោយឪ" ។ នាងង៉ោះជាម្តាយឮអាឡេវជាកូនឃាត់ មិនអោយយំហើយសួរទៅអាឡេវថា "បានរៀបបញ្ចុះខ្មោចឪឯងរួចហើយឬនៅ ?" អាឡេវប្រាប់ម្តាយថា "ខ្ញុំបានពឹងអ្នក

ស្រុកអោយគេជួយរៀបបញ្ចុះខ្មោចឪរួចល្អល្អិតហើយ" ។ នាងដោះឮកូនថាដូច្នោះក៏ម្ចីម្នារៀបធ្វើអន្សមនំគម ចំណីចំណុក ហើយនិយាយនឹងអាឡោវថា "កូនអើយ! ឯងយកនំចំណីនេះទៅធ្វើបុណ្យអោយឪឯងចុះ អញមិនទៅទេបើអញទៅឃើញស្រែដែលឪឯងធ្វើ កន្លែងដែលឪឯងនៅ និងផ្នូរខ្មោចឪឯងនោះ ម្ដាយរឹតជាកើតទុក្ខច្រើនឡើងទៀត បើដូច្នោះឯងទៅចុះ" ។ អាឡោវឮម្ដាយថាដូច្នោះក៏នឹកអរក្នុងចិត្តណាស់ ត្បិតត្រូវនឹងគំនិតខ្លួនដែលកុហកម្ដាយនោះ ហើយម្ចីម្នារៀបសង្រែករួចស្រេចក៏រែកទៅ លុះទៅដល់ពាក់កណ្ដាលផ្លូវ ដាក់អម្រែកពីលើស្មាហើយអង្គុយស៊ីនំ និងចំណីចំណុកលុះត្រាតែឆ្អែត នៅសល់ខ្លះអាឡោវរៀបទុកយកទៅធ្វើឪវាលុះទៅដល់ជិតខ្ទមឪវាៗធ្វើជាយំទៀត ។ អ្នកងេះជាឪពុកឃើញកូនយំហើយសក់ទើបនឹងកោរថ្មីៗដូច្នោះក៏សួរទៅថា "កូនអើយ! ថ្វីក៏ឯងយំហើយកោរទាំងសក់ក្បាលដូច្នេះ ?" ។ អាឡោវប្រាប់ឪពុកថា "ឪអើយ! ឥឡូវនេះម៉ែគាត់ស្លាប់ទៅហើយបានជាខ្ញុំកោរសក់អស់ បងប្អូនគេរៀបធ្វើបុណ្យអោយម៉ែ បានជាមានទាំងនំ ឥឡូវនេះខ្ញុំយកមកធ្វើឪពិសា" ។ ឯឪពុកជាមនុស្សឆោតល្ងង់ណាស់ ឮកូនប្រាប់ដូច្នោះក៏យំអាណិតប្រពន្ធហើយក៏និយាយនឹងអាឡោវថា "កូនអើយ! អំពីថ្ងៃនេះទៅឪពុកលែងទៅទន្លេទៀតហើយ" ។អាឡោវឮថាឪពុកលែងទៅស្រុកដូច្នោះក៏នឹកអរក្នុងចិត្តថាត្រូវនឹងគំនិតខ្លួនគិត ។

លុះយូរបន្តិចទៅអាឡោវនិយាយនឹងអ្នកងេះជាឪពុកថា "ឥឡូវនេះឪនៅតែពីរនាក់នឹងខ្ញុំដូចសព្វថ្ងៃនេះលំបាកណាស់ គ្មានអ្នកណាដណ្ដាំបាយស៊ី គ្មានអ្នកណានឹងដេរសំពត់អាវស្លៀកដណ្ដប់ បើដូច្នោះឪពុកឯងរកដណ្ដឹងប្រពន្ធយកមកគ្រាន់ដាំបាយ ដងទឹក បុកស្រូវ ទើបយើងមិនសូវនឿយហត់ដូចសព្វថ្ងៃពេក" ។ អ្នកងេះជាឪពុកឆ្លើយឡើងថា "ឱកូនអើយ! ម្ដាយឯងស្លាប់ទៅពុំទាន់បានមួយខែទេ ឥឡូវនេះឯងអោយឪរកប្រពន្ធទៀត កូនមិនអាណិតម៉ែឯងទេ ?" មួយទៀតឪខ្មាសគេ ក្រែងគេថាប្រពន្ធស្លាប់មិនទាន់បានប៉ុន្មានថ្ងៃ ប្ដីគិតរកប្រពន្ធថ្មី ឪខ្មាសគេណាស់មិនយកប្រពន្ធទៀតទេ" ។ អាឡោវចេះតែអង្វរឪពុកតែសព្វថ្ងៃ ។ ថ្ងៃមួយអាឡោវឃើញឪពុកមកពីស្រែនឿយហត់ណាស់ វាក៏និយាយថា "ឪអើយ! ឥឡូវនេះឪឯងនឿយណាស់ ព្រោះគ្មានប្រពន្ធនឹងជួយកំលាំង ។ មួយទៀតពាក្យបុរាណលោកថា មនុស្សគ្មានប្រពន្ធដូចឪឯងនេះបើទៅធ្វើការឯព្រៃ បាត់ការឯផ្ទះធ្វើការឯផ្ទះបាត់ការងារឯព្រៃ ធ្វើដូចម្ដេចបានប្រាក់ចាយបាយស៊ីនឹងគេ ហើយខ្លួនក៏នឿយណាស់ផង" ។ អ្នកងេះឮកូនអង្វរដូច្នោះក៏សួរទៅថា "បាននរណាគេទៅដណ្ដឹងប្រពន្ធអោយឪ ?" ។ អាឡោវឆ្លើយឡើងថា "ឪកុំព្រួយសឹមខ្ញុំទៅរកដណ្ដឹងជូនឪ នៅចាំតែរៀបរបស់នឹងគេការចុះ" ។ អ្នកងេះជាឪពុកឮកូនថាដូច្នោះក៏ថា "តាមតែកូនគិតចុះ" ។ អាឡោវឮឪពុកព្រមដូច្នោះហើយ ក៏ត្រៀមខ្លួនម្ចីម្នាទៅផ្ទះនាងដោះជាម្ដាយទៅបានពីរបីថ្ងៃ ទើបវានិយាយនឹងនាងដោះជាម្ដាយថា "ម៉ែអើយ យើងនៅតែពីរនាក់ ខ្ញុំក៏ក្មេងមិនចេះរកស៊ីធ្វើការ ម៉ែជាស្រីហើយមេម៉ាយផងឥឡូវមានគេចង់បានម៉ែៗ យកប្ដីទៅគ្រាន់គេចិញ្ចឹមសោះអត់ឃ្លាន យើងក៏មិនសូវលំបាក" ។ ឯនាងដោះឮអាឡោវជាកូនថាដូច្នោះក៏ឆ្លើយថា "កូនអើយ! ឪឯងទើបតែនឹងស្លាប់បាន ៥-៦ថ្ងៃឥឡូវនេះកូនអោយម្ដាយយកប្ដីទៀត ដូច្នេះមិនត្រូវទេអ្នកផងគេនឹងសើចតិះដៀលនិន្ទាថា ស្រីចើកអាស ប្ដីស្លាប់ពុំទាន់បានប៉ុន្មានថ្ងៃចង់បានប្ដីទៀត" ។ អាឡោវឮម្ដាយថាដូច្នោះក៏ឆ្លើយឡើងថា "ម៉ែអើយ! បើទុកជាម៉ែខ្លាចពាក្យអ្នកផងគេនិន្ទាដូច្នោះ គេក៏មិនបានមករកចិញ្ចឹមយើងដែរ គេបានប្រាក់កាសគេមិនអោយយើងចាយទេ កាលខ្ញុំនៅស្រុកស្រែមានប្រុសម្នាក់មុខមាត់ខ្លួនប្រាណដូចខ្មោចឪហើយគាត់ស្រឡាញ់ខ្ញុំដូចជាកូន គាត់សួរខ្ញុំថាឯងមានម៉ែឪដែរទេ ? ខ្ញុំប្រាប់គាត់ថាគ្មានឪទេមានតែម៉ែ ហើយគាត់និយាយនឹងខ្ញុំថា ចង់បានម៉ែជាប្រពន្ធតើម៉ែឯងព្រមឬដូចម្ដេច?" បើម៉ែព្រមគាត់នឹងរៀបបណ្ដាប់មកចែចូវ មានអ្នកផ្លូវចៅមហាមានខាន់ស្លាក្រយាសំពះតាមច្បាប់សណ្ដាប់ប្រពៃណីពីបុរាណមក បើម៉ែមិនព្រមខ្ញុំក៏មិនដឹងដែរ តែម៉ែគិតធ្វើការរកស៊ីចុះ ។ នាងដោះជាម្ដាយឮកូននិយាយអង្វរផ្ចាញ់ផ្ចាលដូច្នោះក៏ឆ្លើយតបទៅវិញថា "តាមតែកូនគិតចុះ" ។ អាឡោវឮម្ដាយថាតាមតែចិត្តដូច្នោះក៏អរណាស់ គិតថា "អញបាននំស៊ីទៀតហើយ " ហើយរៀបចំផ្ទះសំបែងរួចប្រាប់នាងដោះជាម្ដាយថា "ត្បិតគេចង់រៀបការឆាប់ខ្ញុំលាម៉ែ

ទៅស្រែដើម្បីរកមាន់ទាបន្លែបង្ការ ហើយនឹងប្រាប់អ្នកដែលចង់បានម៉ែជាប្រពន្ធនោះផង ដើម្បីអោយគេរករណ្តាប់រៀបការ" ។ អាឡេវក៏ម្នីម្នារៀបខ្លួនទៅស្រែលុះទៅដល់ហើយក៏និយាយប្រាប់អ្នកង៉េះជាឪពុកថា "ឪអើយ ! ខ្ញុំទៅរកប្រពន្ធអោយឪបានហើយនាងនោះមុខមាត់សំដីសំដៅកំពស់កំពសំបុរសំបកដូចម៉ែបេះបិទ ឥឡូវនេះខ្ញុំអោយគាត់មកនៅលើផ្ទះយើងហើយ បើដូច្នេះឪរៀបរណ្តាប់ទៅការអោយឆាប់" ។ អ្នកង៉េះឮអាឡេវប្រាប់ថាគេអោយរៀបការជាឆាប់ដូច្នេះ ក៏ម្នីម្នាពឹងអ្នកស្រុកផ្ទះជិតខាងអោយជួយធ្វើនំនែកចំណីចំណុក ហើយខ្លួនគាត់ទៅរកទិញមាន់ទាបន្លែបង្ការបានសព្វគ្រប់មុខ ។ ឯអាឡេវចេះតែស៊ីនំរាល់ថ្ងៃហើយនិយាយនឹងឪពុកថា "ប្រពន្ធដែលខ្ញុំដណ្តឹងអោយឪនោះ មេបាបើកអោយរៀបការតែយប់ បើមិនដូច្នោះមេបាមិនបើកអោយការទេ" ។ អ្នកង៉េះឮអាឡេវថាដូច្នោះ ហេតុតែជាមនុស្សឆោតល្ងង់តាមតែពាក្យអាឡេវបង្គាប់ក៏តាមទាំងអស់ ទើបរកវេលាទៅរៀបការអោយត្រូវតែវេលាយប់ ។ ពេលល្ងាចអ្នកង៉េះក៏ពឹងអស់បងប្អូនដែលនៅជិតខាង អោយជួយជញ្ជូនអស់បណ្តាការនាំទៅរៀបមង្គលការលុះទៅដល់កន្លែងការក៏រៀបដណ្តាំបាយស្លស្លក អ្នកខ្លះក៏រៀបផ្លែឈើចំណីចំណុកទៅជូនមេបាតាមទំនៀម ។ នាងង៉ោះពឹងអស់បងប្អូនមករៀបបណ្តាការទទួលតាមច្បាប់ ។ ឯអាឡេវតិតតែស៊ីនំអោយឆ្អែត ។ នាងង៉ោះឮមាត់អ្នកង៉េះក៏ឆ្ងល់ក្នុងចិត្តថា "មាត់និយាយនោះដូចជាសំលេងអ្នកង៉េះប្តីអញ" ។ អ្នកង៉េះឮមាត់នាងង៉ោះក៏ឆ្ងល់ក្នុងចិត្តថា "សំលេងនិយាយនោះដូចសំលេងនាងង៉ោះប្រពន្ធអញ" ។ អ្នកង៉េះសង្ស័យណាស់ ក៏ឡើងទៅលើផ្ទះឃើញនាងង៉ោះក៏ថា "នាងនេះដូចនាងង៉ោះប្រពន្ធអញ" ឯនាងង៉ោះថា "អ្នកនេះដូចជាអ្នកង៉េះប្តីអញ" អស់បងប្អូននិងអ្នកស្រុកគេថា "អ្នកង៉េះហើយថាមិនអ្នកង៉េះនាងង៉ោះហើយថាមិនមែននាងង៉ោះ" ។ លុះអ្នកង៉េះ និងនាងង៉ោះ ឃើញគ្នាជាក់មែនទែនហើយទើបដឹងថា អាឡេវវាបញ្ឆោតក៏អៀនរត់ទៅដោយខ្លួនទីទៃៗ ។ អាឡេវដឹងថាម្តាយឪពុកដឹងដូច្នោះក៏វេះពួន ព្រឹកឡើងអាឡេវរត់ទៅនៅវត្តធ្វើជាកូនសិស្សលោក ។ ឯអ្នកង៉េះនិងនាងង៉ោះក៏នៅជាប្តីប្រពន្ធនឹងគ្នាដូចដើមទៅ ។ អាឡេវនៅរៀនអក្សរនិងលោកគ្រូរាជលុះនៅយូរទៅអាឡេវគិតថា "អញនឹងបញ្ឆោតលោកសង្ឃណាដែលមានប្រាក់ច្រើនយកអោយម៉ែឪអញ" ។ អាឡេវគិតដូច្នោះហើយក៏ទៅនិយាយនឹងលោកភិក្ខុកម្លោះមួយអង្គ ដែលមានប្រាក់ច្រើនថា "មានស្រីម្នាក់ស្រឡាញ់លោកគ្រូ ស្រីនោះក្រមុំល្អស្អាតណាស់" ។ លោកឮអាឡេវថាដូច្នោះក៏អរចង់បាន ហើយនិយាយនឹងអាឡេវថា "បើប្រាកដដូចឯងថាមែនអញនឹងអោយប្រាក់ឯងមួយបាត" ។ អាឡេវថា "ចាំដល់ពេលយប់ងងឹតលោកគ្រូនៅចាំកន្លែងនោះ ខ្ញុំករុណានឹងនាំស្រីនោះមក" ហើយវាលាលោកនោះចុះពីលើកុដិដើរតម្រង់ទៅផ្ទះចិនគិតទៅនិយាយបញ្ឆោតចិនទៀត លុះទៅដល់ហើយដើរចូលទៅក្នុងផ្ទះនិយាយថា "ចិកៗចង់បានស្រីក្រមុំល្អដែរឬទេ ?" ។ ចិនឆ្លើយថា "អើអញចង់បាន" ។ អាឡេវថា "បើចិកចង់បាន តើអោយប្រាក់អញប៉ុន្មាន ?" ចិនថា "អញអោយមួយបាត" ។ អាឡេវថា "តិចណាស់បើឲ្យពីរបាតនោះអញរកស្រីក្រមុំសៗល្អៗ អោយចិកឯង" ។

ចិនថា "អើ" អាឡេវថា "បើដូច្នោះចាំពេលយប់ងងឹតអញនឹងនាំមកអោយចិកឯង" ។ ហើយអាឡេវក៏ត្រឡប់ទៅវត្តវិញ លុះដល់វេលាយប់ងងឹតមើលគ្នាមិនស្គាល់វាក៏នាំលោកនោះអោយទៅអង្គុយចាំក្នុងរោងមួយស្ងាត់ ហើយវានិយាយផ្តាំលោកថា "បើខ្ញុំករុណានាំស្រីនោះមកដល់លោកយកចីពរទទូរព្រះកេសអោយជិត" ។ អាឡេវផ្តាំលោកនោះរួចហើយក៏ដើរចូលទៅក្នុងផ្ទះចិនហៅចិននោះចេញមកហើយនិយាយថា "ឥឡូវអញរកស្រីក្រមុំអោយចិកឯងបានហើយ" ។ អាឡេវវាផ្តាំចិនថា "បើចិកឯងចូលទៅដេកនឹងស្រីនោះ ត្រូវទទូរក្បាលអោយជិត" ទើបនាំចិននោះទៅទៀបរោងដែលលោកនៅចាំហើយវាខ្សិបប្រាប់ចិនថា "ស្រីនៅក្នុងនេះហើយអោយប្រាក់មក ចិនមើលក្នុងរោងឃើញលោកអង្គុយទទូរចីពរនៅទីនោះ" គិតស្មានថាជាស្រីមែន ក៏ឲ្យប្រាក់ទៅអាឡេវ ។ អាឡេវបានប្រាក់ហើយ ក៏វេះជាប្រញាប់ត្រឡប់ទៅវត្តវិញ លុះចិននិងលោកបានជួបគ្នា ហើយចិនគិតថាលោកជាស្រី លោកក៏គិតថាចិនជាស្រី ក៏ប្រចាក់គ្នាផ្តួល ។ ដោយលោកអត់ចង្ហាន់ល្ងាចមិនសូវមានកំលាំងក៏ដួលដេកទៅ ចិនពាល់ត្រូវស្មាសលោកក៏ដឹងថាអាឡេវកុហក ។

ទាំងលោកទាំងចិនលុះដឹងថាអាឡេវបញ្ឆោតក៏អៀនទៅកុដិទៅផ្ទះដោយខ្លួនទៅ ។អាឡេវចាំលោកឯកុដិនោះ លុះលោកមកដល់កុដិហើយវាក៏ទារប្រាក់អំពីលោកៗនោះថា“អាឡេវឯងបញ្ឆោតអញហើយ ឯងមកទារប្រាក់ពីអញទៀតអញមិនអោយឯងទេ” ។

អាឡេវថា“បើលោកមិនអោយប្រាក់ទេ ខ្ញុំករុណានឹងទៅពិតលោកគ្រូធំថាលោកទៅដេកនឹងស្រី ហើយនឹងទៅប្រាប់អស់ឧបាសកទាយកអ្នកស្រុក ក្នុងភូមិទាំងអស់ឲ្យគេដឹងទៀត បើគេដឹងហើយ គេមិនអោយបាយលោកឆាន់ទេ ហើយលោកក៏នឹងខ្មាសគេនៅវត្តជាមួយគេពុំបាន មួយទៀត បើខ្ញុំករុណាទៅប្ដឹងដល់ក្រុមសង្ឃការី មុខជាគេនឹងមកចាប់លោកយកទៅជំនុំជំរះពិចារណា តាមដំណើរដែលលោកជួលខ្ញុំករុណាឲ្យរកស្រីហើយលោកថាអោយប្រាក់ខ្ញុំករុណាមួយបាតឥឡូវនេះ លោកមានដេកនឹងស្រីហើយលោកគេចថាមិនអោយវិញ ខ្ញុំករុណាមិនលែងលោកទេ! មុខជាទៅពិតលោកគ្រូធំហើយ” ។ លោកនោះឮអាឡេវថាដូច្នោះក៏ភិតភ័យខ្លាំងណាស់យកប្រាក់មួយបាតអោយទៅអាឡេវជាប្រញាប់ ។ អាឡេវមិនព្រមទទួលយកវាថា“កាលលោកនិយាយនោះថា អោយប្រាក់មួយបាត្រដែលឆាន់បាយថ្ងៃ ។ ឥឡូវត្រូវលោកយកប្រាក់វាល់ពេញបាត្រ ទើបខ្ញុំករុណាទទួលយក បើលោកមិនរកអោយទេ នឹងទៅពិតលោកគ្រូធំថាលោកទៅដេកនឹងស្រីពីយប់មិញ លោកគ្រូធំជ្រាប ហើយនឹងចាប់លោកយកទៅវាយបណ្ដេញមិនអោយនៅក្នុងវត្ត មួយទៀត ខ្ញុំករុណានឹងទៅប្ដឹងលោកឧកញ៉ាព្រះស្ដេចជាធំ ក្នុងក្រុមសង្ឃការីអោយមកចាប់យកទៅ ពួកសង្ឃការី គេនឹងយកសំពត់បោកក្បាលលោកផ្សឹកចេញពីសង្ឃ ហើយដាក់ជាពលរាជនិមន្ត ពុំនោះសោតគេនឹងដាក់ជាពលបោចស្មៅដំរី” ។ លោកឮអាឡេវថាដូច្នេះ ក៏ភិតភ័យណាស់អង្វរថា“ចាំរកប្រាក់អោយកុំទៅពិតលោកគ្រូធំ និងកុំទៅប្ដឹងក្រុមសង្ឃការីឡើយ”ហើយខំរកប្រាក់លក់ស្បង់ចីពរផ្សេងៗអោយអាឡេវ ។ អាឡេវឃើញលោកលក់ស្បង់ចីពរ ផ្សេងៗប្រាក់អោយដូច្នេះ ក៏និយាយនឹងលោកថា“ល្មើយលោករកប្រាក់អោយខ្ញុំករុណា ល្មមតែ



ស្ពាយទៅផ្ទះរួចបានហើយ” ។ លោកឮអាឡេវថាដូច្នោះ ក៏មានចិត្តត្រេកអរណាស់រៀបវេចប្រាក់មួយសម្ពាយអោយអាឡេវ ហើយនិយាយអង្វរថា កុំអោយនិយាយប្រាប់គេអោយដឹង ឯងអាណិតយកតែបុណ្យទៅចុះ ។ អាឡេវថា“លោកកុំព្រួយព្រះទ័យខ្ញុំករុណាមិនប្រាប់គេទេ” ហើយទទួលយកប្រាក់ពីលោកដើរទៅផ្ទះ ។

លុះទៅដល់ផ្ទះជួបនឹងម្ដាយ អាឡេវក៏ស្រែកប្រាប់ម្ដាយថា“ម៉ែដេរថង់ៗ”នាងង៉ោះឮហើយសួរទៅថា“ដេរធ្វើអ្វី ?” ។ អាឡេវបង្ហាញប្រាក់ដែលស្ពាយ ។ នាងង៉ោះជាម្ដាយ ឃើញអាឡេវបានប្រាក់មួយសម្ពាយដូច្នេះ ក៏ស្ទុះទៅប្រាប់អ្នកង៉េះជាប្ដី ។ អ្នកង៉េះមកឃើញអាឡេវបានប្រាក់មួយសម្ពាយ ក៏បាត់ខឹងនឹងអាឡេវដែលបញ្ឆោតអំពីមុននោះអរនឹងអាឡេវទាំងម្ដាយឪពុក ហើយអ្នកង៉េះសួរទៅអាឡេវថា“កូនបានប្រាក់នេះពីណាមក កូនធ្វើដូចម្ដេចបានជាបាន ?” ។ អាឡេវប្រាប់ទៅឪវាថា“ក្រអឺសពូបើប្រាក់គ្រាន់តែបង្ហាញកេរ្ដិ៍ខ្មាសអោយអ្នកផ្សារមើលគ្រប់គ្នា ខ្លះគេអោយមួយបាត ខ្លះ ពីរបាតតែរាល់គ្នាដូច្នោះទៅ ក៏បានច្រើនហើយ បើឪចង់បានប្រាក់ច្រើនទៅបង្ហាញកេរ្ដិ៍ខ្មាសអោយអ្នកផ្សារមើលម្ដងម្នាក់ទៅ ឪយកប្រាក់មិនអស់” ។ អ្នកង៉េះជាឪពុកឮអាឡេវថាដូច្នោះហើយ ហេតុតែគាត់ជាមនុស្សឆោតល្ងង់ក៏ទៅធ្វើតាមពាក្យអាឡេវ លុះទៅផ្សារក៏ឈរនៅមាត់ទ្វារផ្ទះគេបង្ហាញកេរ្ដិ៍ខ្មាស ។ អ្នកផ្ទះឃើញដូច្នេះក៏អៀនខ្មាសបបួលគ្នាដេញវាយ ។ អ្នកង៉េះចេញពីផ្ទះមួយចូលផ្ទះមួយទៀត ហើយបង្ហាញកេរ្ដិ៍ខ្មាសគេទៀត គេដេញវាយស្ទើរតែស្លាប់ អ្នកង៉េះភ័យរត់ទៅផ្ទះ ។ ឯអាឡេវចាំមើលឪពុកកណ្ដាលផ្លូវ ឃើញឪពុករត់មកពីផ្សារ ហើញជួនជាមានជាស្ពាយទំនិញព្រៃហូលប្រអប់ប្រាក់មាសជាច្រើនមកអំពីចម្ងាយ ក៏ប្រាប់ទៅអ្នកង៉េះជាឪពុកថា“ហ៎ឪ! អ្នកផ្សារគេតាមមកវាយឪហើយបើដូច្នេះឪរត់កាត់វាលនេះទៅទើបរួចខ្លួន” ។ អ្នកង៉េះឮកូនប្រាប់ដូច្នេះ ក៏ក្រឡេកមើលទៅឃើញមនុស្សដើរអំពីចម្ងាយមកមែន គាត់គិតស្មានថាជាអ្នកផ្សារគេតាមមកវាយទៀត ក៏ភ័យណាស់រត់តាមពាក្យអាឡេវទៅទៀត ទៅឆ្ងាយល្មមតែមើលឃើញ ។

ជ្វាដែលស្ពាយទំនិញនោះក៏មកដល់ ។ អាឡេវគិតបញ្ឆោតជ្វានោះទៀត វានិយាយប្រាប់ថា "បងធម្មអើយ! មានគេដេញក្តាន់បាក់ជើងម្ខាង ប៉ុន្តែអ្នកដេញនោះតែម្នាក់ឯង និងខ្ចប់ចាប់ពុំបាន បើដូច្នេះបងធម្មឯងរត់ទៅជួយចាប់បើបាននឹងយកមកចែកគ្នាស្ងួស៊ី" ។ ជ្វាឮអាឡេវប្រាប់ដូច្នោះ ក៏ក្រឡេកមើលទៅតាមពាក្យអាឡេវឃើញមនុស្សរត់គិតស្មានថា ជាមនុស្សដេញក្តាន់មែន ក៏យកសម្ពាយផ្ញើទុកនឹងអាឡេវទាំងអស់ ហើយបបួលគ្នារត់ទៅតាមអ្នកងេះៗ រត់បណ្តើរក្រឡេកមើលមកក្រោយបណ្តើរ ឃើញជ្វារត់តាមក្រោយ គិតស្មានថាជាគេដេញចាប់ខ្លួនក៏ប្រឹងរត់ទៅទៀត ។

ឯអាឡេវបានសម្ពាយទ្រព្យរបស់ជ្វាហើយ ក៏ជញ្ជូនយកទៅលាក់ទុកអោយម៉ែវា ហើយវាវេះរត់អំពីទីនោះទៅទៀត ។ ឯជ្វាដល់ដឹងថាអាឡេវបញ្ឆោតដូច្នោះក៏ត្រឡប់មកវិញរកសម្ពាយទំនិញនិងអាឡេវពុំឃើញ នឹកស្តាយរបស់នោះណាស់និងរកចាប់អ្នកឯណាពុំបាន ក៏ខំដើរទៅរកអាឡេវ ។

សូមស្លេះត្រឹមនេះសិន ។

សូមថែងពីរឿងអាឡេវដែលរត់ទៅនោះវិញ ។

ឯអាឡេវកបលក្រោយនោះរត់ទៅដល់ស្រុកមួយឆ្ងាយណាស់ហើយ បានជួបនឹងដូនចាស់ម្នាក់ និង ចៅក្រមុំម្នាក់ កំពុងរៀបទូកផ្ទុករបស់ទ្រព្យដើម្បីទៅនៅស្រុកឯទៀតអោយជិតជុំនឹងអស់បងប្អូនញាតិសន្តាន ត្បិតចៅគាត់ក្រមុំល្មមអោយមានប្តីហើយ ។ អាឡេវឃើញចៅដូនចាស់នោះ ក៏មានចិត្តស្រឡាញ់ហើយជួយជញ្ជូនរបស់ទ្រព្យដាក់ទូក ។

ដូនចាស់ឃើញអាឡេវជួយឈឺឆ្អាលដូច្នោះគាត់សួរថា "ចៅទៅណា ?" ។ អាឡេវប្រាប់ថា "ខ្ញុំសូមដោយសារយាយទៅផង" ។ ដូនចាស់នោះសួរថា "ចៅឯងឈ្មោះអ្វី ?" ។ អាឡេវប្រាប់ថា "ខ្ញុំឈ្មោះជីចៅប្រសា បើយាយទៅណាខ្ញុំសូមដោយសារទៅផង" ។ យាយចាស់ឮអាឡេវសុំដោយសារដូច្នោះក៏មានចិត្តអរនឹកថាបានជាគ្នា គ្រាន់នឹងជួយចែវទូកទៅ ។ លុះរៀបរបស់ទ្រព្យរួចស្រេចកាលណាអាឡេវក៏សុំខ្លួនចែវទូក ។



ឯដូនចាស់អង្គុយអុំក្បាល ចៅក្រមុំអង្គុយកណ្តាល អាឡេវ និងចៅក្រមុំ ចេះតែរំពៃមើលមុខគ្នាហើយញញឹមទៅមករកគ្នា ។

លុះចែវបន្តិចទៅ អាឡេវធ្វើជាភ្លេចកាំបិត ក៏និយាយថា "ឱយាយអើយខ្ញុំភ្លេចកាំបិតចោលនៅលើគោកឯក្រោយនោះ ត្បិតខ្ញុំរវល់តែជញ្ជូនតែរបស់យាយបានជាខ្ញុំភ្លេចកាំបិតខ្ញុំ កាំបិតនោះជារបស់កេរ្តិ៍កោះពីម៉ែឪដូនតាមក ដូច្នេះខ្ញុំសុំត្រឡប់ទូកទៅយកវិញ" ។ ដូនចាស់ក៏ព្រមត្រឡប់ទូកទៅវិញ លុះដល់កំពង់អាឡេវនិយាយនឹងដូនចាស់ថា "យាយអាណិតឡើងទៅយកកាំបិតអោយចៅបន្តិច ខ្ញុំទុកត្រង់គល់ឈើខាងលើច្រាំងនៅប្រឋផ្លូវ ដែលយើងជញ្ជូនរបស់មកនោះ" ។ អាឡេវបញ្ឆោតយាយចាស់អោយតែគាត់ឡើងទៅផុតកាលណា នឹងចេញទូកអុំរត់យកចៅក្រមុំ ។ លុះដូនចាស់ឡើងដល់មាត់ច្រាំងល្មមកំបាំងភ្នែក អាឡេវក៏ម្នីម្នាថយទូកជាប្រញាប់ចោលដូនចាស់នោះ ហើយខំចែវបណ្តោយតាមទឹកហូរទៅ ។

យាយចាស់នោះលុះរកកាំបិតពុំឃើញ ក៏ត្រឡប់មករកទូកវិញ បាត់ទាំងអាឡេវបាត់ទាំងចៅក្រមុំ ក្រឡេកមើលទៅក្រោមទឹកឃើញអាឡេវវាកំពុងចែវទូក ដូនចាស់ភ័យណាស់ យកដៃគក់ទ្រូងស្រែកទ្រហោយំរត់តាមទៅ ហើយស្រែកប្រាប់អ្នកស្រុកថា "សូមជួយផងត្បិតចៅប្រសាវាលួចពង្រត់ចៅក្រមុំខ្ញុំ" ។ រត់បណ្តើរស្រែកបណ្តើរអោយអ្នកស្រុកគេជួយតាមថា "ត្បិតជីចៅប្រសាវាលួចរត់ចៅក្រមុំទៅ" ។ អស់អ្នកស្រុកគេឮថាចៅប្រសានាំពង្រត់ចៅក្រមុំដូច្នោះ គ្មាននរណាគេជួយគេគិតថាប្រពន្ធរបស់អាឡេវ ។ លុះដូនចាស់រត់តាមពុំទាន់ទើបរាយដំណើរប្រាប់អ្នកស្រុកថា "អាដែលលួចចៅក្រមុំខ្ញុំនោះ វាឈ្មោះជីចៅប្រសា វាមិនមែនជាចៅប្រសាខ្ញុំទេ វាលួចពង្រត់ចៅក្រមុំ និងទ្រព្យខ្ញុំទៅទេតើ" ។ ទើបអ្នកស្រុកគេដឹងរាល់គ្នាថាអាឡេវវាបញ្ឆោតលួចពង្រត់ចៅក្រមុំនិងរបស់ទ្រព្យយាយដូច្នោះ ក៏គេមិនដឹងធ្វើដូចម្តេចនឹងទៅតាមក៏មិនទាន់ ត្បិតវាទៅឆ្ងាយណាស់ហើយ ។ ឯអាឡេវខំចែវលុះដល់វេលាយប់និយាយលួងលោមនាងក្រមុំនោះថា "បានជាបងខំពង្រត់មកត្បិតបងស្រឡាញ់នាងណាស់ ឥឡូវនេះបងយកនាង

ធ្វើប្រពន្ធ" ។ នាងក្រមុំនោះចេះតែកន្ទក់កន្ទេញរព្ញកជីដូន ត្បិតធ្លាប់នៅតែពីរនាក់ ហើយនិយាយប្រាប់អាឡេវថា "ម្លេះសមជីដូនគាត់រកខ្ញុំមិនឃើញ គាត់នឹងលោតទឹកសំលាប់ខ្លួន ក៏មិនដឹង ? មួយទៀតសមគាត់នឹករលឹកខ្ញុំ គាត់សង្រេងសង្រៃអត់បាយទៅឈឺស្លាប់អសារឥតការ បើដូច្នេះសូមអ្នកជូនខ្ញុំទៅវិញ បើអ្នកមិនជូនខ្ញុំទៅទេខ្ញុំនឹងលោតទឹកសំលាប់ខ្លួន" ។

អាឡេវឮនាងនោះនិយាយដូច្នោះ ក៏វាតទូកចូលក្នុងព្រៃស្វាត់លួងលោមនាងនោះថា "បងស្រឡាញ់នាងណាស់ ហើយបានជាបងខំពង្រត់យកមកធ្វើជាប្រពន្ធ បើនាងលោតទឹកសំលាប់ខ្លួនដូច្នោះ តើបងបាននរណាជាប្រពន្ធ" ។ នាងឆ្លើយឡើងថា "បើអ្នកស្រឡាញ់ម្តេចក៏អ្នកមិនដណ្តឹងតាមច្បាប់ ?" ។ អាឡេវឆ្លើយថា "ឱនាងអើយ! បើចាំដណ្តឹងតាមច្បាប់ ធ្វើម្តេចនឹងឆាប់បានទាន់ចិត្តបើគេអោយនោះក៏បាន បើគេមិនអោយនោះនឹងទទេឥតអំពើ ដូច្នោះហើយបានជាបងនាំពង្រត់នាងសិន ទៅដល់ស្រុកម៉ែឪដូនតានឹងរៀបការតាមច្បាប់ ។ នាងកុំព្រួយចិត្តបងនឹងជូនទៅសួរជីដូននាងជាប្រញាប់ កុំនាំងថប់បារម្ភឡើយ" ។ នាងក្រមុំព្រមព្រៀងសុខចិត្តធ្វើជាប្រពន្ធអាឡេវទៅ ។

លុះព្រឹកឡើងអាឡេវក៏ចែវទូកទៅទៀតប្រទះនឹងចោរ ៥០០នាក់ ។ ចោរទាំង៥០០នោះតែងទៅចាំប្លន់ទូកអ្នកដំណើរ ដែលដើរទៅរកស៊ីតែសព្វថ្ងៃ ។ លុះឃើញទូកចែវទៅដល់ ក៏គិតប្លន់យកទ្រព្យរបស់ ។ អាឡេវដឹងថាចោរចាំប្លន់យកទ្រព្យរបស់ខ្លួនដូច្នោះ ក៏ចូលទូកទៅក្នុងកណ្តាលពួកចោរ ហើយឡើងទៅនិយាយនឹងមេចោរថា "អស់អ្នករាល់គ្នាហ៊ានប្លន់តែអ្នកទូកអ្នកដំណើរ ដែលដើររកស៊ីដាច់ដោចឆ្ងាយពីស្រុកពីភូមិគេហើយលើកគ្នាទៅទាំងហ្វូងៗផង ឯខ្លួនមិនចេះប្លន់អ្នកដើររកស៊ីដាច់ដោចដូច្នេះទេ ខ្ញុំប្លន់តែអ្នកស្រុកអ្នកនគរ ហើយខ្លួនតែម្នាក់ឯងបានជាខ្ញុំហ៊ានដូច្នេះ ដោយខ្ញុំចេះអាគមកាប់មិនមុតដុតមិនឆេះ ហើយចេះទាំងអាគមបបមាំម៉ឺនប៉ែតដានសារដានមហាស្រឡប់ មហាស្រឡាយ នារាយណ៍បែងភាគនារាយណ៍កាឡាំ ខ្ញុំចេះអស់មិនសល់



នេះ ខ្ញុំទើបមកពីប្លន់ស្រុកគេយកបានទាំងកូនក្រមុំគេម្នាក់មកផង បើអ្នកឯងមិនជឿអ្នកសួរស្រីនោះចុះ" ។

អស់ពួកចោរ បានស្តាប់អាឡេវអួតប្រាប់ពីសិល្បសាស្ត្រអាគមវិជ្ជាការដូច្នេះ ហើយក៏ចង់រៀនទើបនិយាយនឹងអាឡេវថា "បើដូច្នោះសូមអ្នកបង្ហាញអាគមសិល្បសាស្ត្រដល់យើងរាល់គ្នាផង យើងសុំអ្នកធ្វើជាគ្រូប្រដៅ ហើយនៅរកស៊ីជាមួយគ្នា ។ អាឡេវថាបើអ្នករាល់គ្នាចង់រៀន ក៏ខ្ញុំបង្ហាញបានប៉ុន្តែការរកទីធ្វើពិធីត្រណមនោះក្រណាស់ មានតែរកកោះដាច់ពីស្រុកភូមិគេហើយនៅកណ្តាលទន្លេឆ្ងាយពីត្រើយនោះទើបធ្វើបាន" ហើយអាឡេវ និង ចោរក៏នាំគ្នាទៅរកកោះកណ្តាលសមុទ្របានឃើញនោះមួយមានផ្ទុកខ្សាច់ល្អ ក៏ឡើងទៅកោះនោះរកមើលទីកន្លែងគួរសមឆ្ងាយពីទីកន្លែងចតសំពៅ ។ អាឡេវប្រាប់ថា "បើអ្នកចង់ចេះអាគមអោយពូកែនោះត្រូវស្តាប់ខ្ញុំបើខ្ញុំបង្គាប់អោយធ្វើអីត្រូវធ្វើតាមពាក្យខ្ញុំទាំងអស់នោះទើបបានអាគមពូកែឆុតឆាប់ " ។ អស់ចោរទាំង៥០០ក៏ទទួលព្រមធ្វើតាមទាំងអស់ហើយអាឡេវបង្គាប់អោយធ្វើរោងពិធីមានបាយសីមាទៀនធូបភ្ញីផ្កាហើយដែលមានជ័រតិឆត្រទង់សង់ជារាង៧ថ្នាក់ហើយវាអោយជីកកកាយដីខ្សាច់ជាអណ្តូងធំជ្រៅអោយមានទឹកល្មមមុជលិចក្បាល លុះធ្វើស្រេចហើយវាបង្គាប់ចោរទាំង៥០០នាក់អោយគោរសក់អោយស្រោតសំពត់ចេញទាំងអស់គ្នា ហើយវានិយាយបញ្ឆោតចោរទាំង៥០០នោះថា "វីអាគមខ្ញុំដែលនឹងរៀននេះត្រូវមុជទឹក ហើយនឹកសូត្រអត់ដង្ហើមនៅក្នុងទឹកបាន៧ចប់ ទើបពូកែមែនទែន" ។ ពួកចោរក៏នាំគ្នាហាត់មុជទឹកសូត្រអាគម ។ ឯអាឡេវចុះទៅសំពៅនិយាយខ្សឹបប្រាប់ប្រពន្ធអោយរៀបចំខ្លួនហើយទាញពួរយុថ្កាអោយខ្លី វាផ្តាំប្រពន្ធថា បើអញរត់ចុះពីលើគោកត្រូវទាញពួរយុថ្កាឡើងជាឆាប់ "ផ្តាំស្រេចហើយក៏ត្រឡប់ទៅវិញ លុះដល់ព្រលប់យប់ងងឹតវាឲ្យពួកចោរមុជទឹកហើយបង្គាប់ថា បើមុជទឹកត្រូវមុជអោយព្រមគ្នា បើងើបៗអោយព្រមគ្នាទើបអាគមពូកែ" ។ លុះពួកចោរមុជព្រមគ្នាហើយអាឡេវរត់ចុះទៅសំពៅដកយុថ្កាលាក្តោង ជួនជាខ្យល់ជំនោរមកដល់អាឡេវបើកក្តោងយោងទាំងសំ

បានទៅចោលចោរទាំង៥០០អោយនៅលើកោះនោះ ។ ឯចោរទាំង៥០០ដើបអំពីទឹកឡើង រកមើលអាឡេវមិនឃើញក៏សួរគ្នាថា "លោកគ្រូទៅណា ?" នាំគ្នារកក្នុងរោងពិធីមិនឃើញ ក៏ចុះទៅមើលឯកំពង់ក៏មិនឃើញ បាត់ទាំងសំពៅ ទាំងមនុស្ស ។ ពួកចោរទាំង៥០០ក៏ដឹងថាអាឡេវបញ្ឆោតហើយទើបនាំគ្នារកឈើឫស្សីធ្វើក្បូនឆ្លង ។

អាឡេវបើកសំពៅយកទ្រព្យរបស់ចោរទាំង៥០០ដែលនៅក្នុងសំពៅនោះទៅតែពីរនាក់ប្ដីប្រពន្ធ លុះបើកក្ដោងទៅអស់មួយយប់មួយថ្ងៃ ក៏បានដល់ស្រុកមួយហើយវារកមើលមនុស្សក្នុងស្រុកនោះពុំឃើញមានមនុស្សប្រុសមានតែមនុស្សស្រីទើបដឹងថាជាស្រុកចោរ ដែលវាបញ្ឆោតនោះហើយ វាបោះយុថ្កាឈប់ ។ អស់ប្រពន្ធចោរទាំងនោះនឹងបានដឹងស្គាល់ថាជាសំពៅរបស់ប្ដីក៏ទេ ត្បិតកាលដែលប្ដីចេញទៅអំពីផ្ទះតែខ្លួនទទេ លុះបានជួបនឹងឈ្មួញសំពៅក៏ប្លន់យកបានជាប្រពន្ធកូនមិនដឹងមិនស្គាល់ ។ លុះអាឡេវបោះយុថ្ការួចស្រេចហើយក៏យកដីសនិងក្ដារឈ្នួនចេញមកក្រៅហើយធ្វើជាគូសវាសចាប់យាម ។ អស់ប្រពន្ធកូនចៅចោរមើលមកឃើញអាឡេវគូសវាសដូច្នេះ ក៏នឹកស្មានថាវាចេះចាប់យាម ទើបសួរថា "អ្នកអើយ! អ្នកចេះចាប់យាមអាណិតមើលអោយប្ដីខ្ញុំបន្តិច ត្បិតគាត់ទៅរកស៊ីជាយូរខែមកហើយ" ។ អាឡេវឮដូច្នេះហើយក៏ដឹងច្បាស់ថា ស្រីទាំងនេះជាប្រពន្ធចោរដែលអញបញ្ឆោតនោះប្រាកដហើយ វាឆ្លើយឡើងថា "គ្រអីសព្វបើចាប់យាមនោះ ទោះបីសម្ដងឬសម្ភារភ្លឹកអត្ថៈលេខយន្តអ្វីក៏ខ្ញុំចេះទាំងអស់ អ្នកចង់មើលអំពីរឿងអ្វី យកតែទៀនធូបស្លាម្លូមកបូជាគ្រូកុំអោយសាបអាគមយាមខ្ញុំតាមគ្រូប្រដៅខ្ញុំមក" ។ ឯប្រពន្ធចោរឮអាឡេវថាដូច្នេះ ក៏ម្ចីម្នាឡើងទៅផ្ទះប្រញាប់ប្រាប់ប្រពន្ធចោរឯទៀតឲ្យរកទៀនធូបភ្ញីផ្កាស្លាម្លូចេកអំពៅ យកទៅជូនគ្រូ ។ អាឡេវទទួលជំនូនហើយតាំងយកក្ដារឈ្នួនមកគូសវាសធ្វើជាចាប់យាមគិតប្រមាណក្នុងចិត្តអោយត្រូវពេលវេលាល្មមពួកចោរទាំង៥០០នោះដល់ផ្ទះ គឺវាគិតប្រមាណត្មេរចម្ងាយផ្លូវហើយប្រាប់ប្រពន្ធចោរថា "ប្ដីអស់អ្នករាល់គ្នានឹងមកដល់ឆាប់ក្នុងថ្ងៃស្អែកនេះប៉ុន្តែក្នុងវេលាយប់នេះនឹងមានព្រាយក្បាលត្រងោលអាក្រាតសំពត់រត់ចូលមកក្នុងផ្ទះបង្កើតជាឧត្បាតធំណាស់ បើដូច្នេះមានតែអ្នករាល់គ្នាគិតរម្ងាប់ឧត្បាតចេញទើបជា" ។ ឯអស់ប្រពន្ធកូនចោរទាំង៥០០ឮអាឡេវថាដូច្នេះក៏ភ័យហើយសួរថា "គិតធ្វើដូម្ដេចនឹងរម្ងាប់ឧត្បាតចេញបាន?" ។ អាឡេវឆ្លើយឡើងថា "វាងាយទេការរម្ងាប់ឧត្បាតនោះគឺដល់វេលាព្រលប់កាលណា ត្រូវអស់អ្នករាល់គ្នានាំកូនចៅកាន់ដំបងព្រនង់នៅចាំមាត់ទ្វារផ្ទះបើឃើញព្រាយក្បាលត្រងោលអាក្រាតសំពត់រត់ចូលមកក្នុងផ្ទះ ត្រូវវាយកុំអោយវាចូលបាន" ។ ឯពួកចោរទាំង៥០០នោះ លុះឆ្លងរួចដល់ត្រើយកាលណាវេលាថ្ងៃពួនព្រៃ យប់នាំគ្នាដើរកាត់តម្រង់មកផ្ទះ ព្រោះគ្មានសំពត់ស្លៀកពាក់បានជាមិនចេញដើរពេលថ្ងៃ ។ លុះដល់ថ្ងៃកំណត់ដែលអាឡេវចាប់យាមក្នុងពេលព្រលប់ពួកចោរក៏មកដល់ផ្ទះខ្លួន ។

ឯកូនប្រពន្ធដែលកាន់ដំបងព្រនង់ចាំនៅមាត់ទ្វារ ឃើញប្ដីរត់ចូលមកក្នុងផ្ទះគិតស្មានថាជាព្រាយក្បាលត្រងោលមែន ក៏ពីតតែវាយទាល់តែដួលសន្លប់ខ្លះ របួសពិការខ្លះក្រោយមកទើបដឹងថាជាប្ដី ជាឪពុកខ្លួន ហើយនិយាយតាមដំណើរប្រាប់ប្ដីសព្វគ្រប់ ។ ពួកចោរទាំង៥០០ខឹងនឹងអាឡេវខ្លាំងណាស់តែមិនដឹងគិតធ្វើដូចម្ដេច ព្រោះខ្លួនត្រូវដំបងដំណំទាំងអស់គ្នា ហើយមិនដឹងជាអាឡេវនៅឯណា ។ វេលានោះអាឡេវនៅចាំស្ដាប់ប្រពន្ធកូនចោរវាយប្ដីខ្លួន ដល់ឮមាត់ស្រែកទ្រហឹងពេញពាសទាំងស្រុក ក៏បើកសំពៅទៅស្រុកប្រពន្ធវិញ លុះទៅដល់ហើយអាឡេវនិងប្រពន្ធឡើងទៅរកជីដូន បានជួបនឹងជីដូនក៏សំពះសូមទោស ហើយប្រគល់របស់ទ្រព្យក្នុងសំពៅទាំងប៉ុន្មានៗជូនជីដូនទាំងអស់ ជីដូនបានឃើញសម្បត្តិអាឡេវពេញសំពៅក៏បាត់ខឹងបែរជាស្រឡាញ់រាប់អានអាឡេវជាចៅប្រសាមែនទែន ។ អាឡេវរៀបសង់ផ្ទះលោះខ្ញុំកំដរពាសពេញក្នុងផ្ទះអោយបំរើជីដូនក្មេកនឹងប្រពន្ធលុះនៅយូរបន្តិចមកក៏លាជីដូននិងប្រពន្ធទៅសួរម្ដាយឪពុកវា ។ ជីដូនក្មេកផ្ដាំថាបើចៅទៅកុំនៅយូរពេកឆាប់ត្រឡប់មករកជីដូនវិញ ត្បិតសព្វថ្ងៃនេះកំព្រាឥតមានអ្នកឯណាជាទីពឹងទេ ។

ឯប្រពន្ធអាឡេវចង់តាមអាឡេវទៅដែរ ក៏និយាយថា“ខ្ញុំចង់ទៅជាមួយនិងអ្នក អោយស្គាល់ម៉ែឪបងប្អូនញាតិសន្តានស្រុកទេសអ្នក មួយទៀតខ្ញុំមិនចង់ឃ្លាតឆ្ងាយពីអ្នកទេ ត្បិតថាប្តីទៅឆ្ងាយហើយកម្រនិងទុកដាក់រក្សាខ្លួនណាស់ អ្នកផងគេតែងនិន្ទាថាដូចជាស្រីមេម៉ាយចំណាយមាត់គេ ហេតុដូច្នេះបានជាខ្ញុំមិនចង់នៅចង់ទៅតាមអ្នកជាប្តី”។ អាឡេវឆ្លើយថា“នាងអើយ! បងចង់បាននាងទៅជាមួយដែរប៉ុន្តែអាណិតជីដូនត្បិតគាត់ចាស់ជរាណាស់ហើយក្រែងឈឺចាប់យប់ថ្ងៃគ្មាននរណាថែទាំបីបមរក្សាដុសថ្នាំចាំជំងឺ និង ទុកចិត្តលើមនុស្សម្នាក់ខ្ញុំកំដរបានទេ ដូចកាលយើងនាំគ្នារត់ទៅនោះគាត់សន្ទឹងសន្ធៃឈឺរីងរៃស្គាំងស្គមទើបនឹងបានគ្រាន់បើ ឥឡូវនេះបើយើងទៅចោលគាត់ទៀតគាត់នឹងឈឺស្លាប់ពុំខានឡើយ ពីមុនបានជាខុសឆ្គងម្តងទៅហើយ ឥឡូវនេះយើងគិតកុំអោយខុសឆ្គងម្តងទៀត”។ ឯប្រពន្ធឮប្តីថាដូច្នេះនឹកអាណិតជីដូន ក៏ព្រមអោយប្តីទៅ ទើបរៀបស្បៀងរាងទៃ សំរាប់បរិភោគតាមផ្លូវសព្វគ្រប់ហើយ សួរប្តីថា“អ្នកនឹងយកមនុស្សម្នារទេះសាឡីទៅប៉ុន្មាន ?”។ អាឡេវឆ្លើយថា“ខ្ញុំមិនយកទៅទេបងទៅតែម្នាក់ឯង”។ ឯគំនិតអាឡេវបានជាមិនចង់យកមនុស្សម្នាទៅពីព្រោះគិតចង់បានប្រពន្ធច្រើន បើនិងយកមនុស្សតាម ក្រែងគេដឹងថាខ្លួនមានប្រពន្ធហើយ នឹងទៅដណ្តឹងកូនគេទៀត ក្រែងគេមិនឲ្យ ហើយវានិយាយនិងប្រពន្ធថា“បងធ្លាប់ដើរតែម្នាក់ឯង តែមានមនុស្សម្នាក្របីគោរទេះទៅជាមួយផង និងធ្វើដំណើរមិនរហ័សទាន់ចិត្ត ហេតុដូច្នេះបានជាបងមិនចង់យកទៅ”។ អាឡេវវេចតែប្រាក់ និង ស្បៀងគ្រាន់នឹងស៊ីតាមផ្លូវ។ ឯជីដូនផ្តាំហើយផ្តាំទៀតថា“បើចៅទៅដល់ម្តាយឪពុកនៅជាសុខសប្បាយ ចូរចៅឆាប់ត្រឡប់មកវិញណាចៅណា!”។ អាឡេវក៏លាជីដូននិងប្រពន្ធហើយចេញដំណើរទៅលុះទៅដល់ផ្ទះអ្នកង៉េះនិងនាងង៉ោះជាឪពុកម្តាយហើយក៏យកប្រាក់ទៅជូនម្តាយឪពុកៗមានចិត្តត្រេកអរសួរថាកូនទៅណាបាត់យូរម្លេះ?។

“ម្តាយឪពុកចេះតែទន្ទឹងមើលផ្លូវកូនតែសព្វថ្ងៃ” ។ អាឡេវប្រាប់ថា“ខ្ញុំទៅគិតការរកស៊ីត្បិតម៉ែឪឯងមិនគិតរកស៊ីនឹងគេ” អ្នកង៉េះនិងនាងង៉ោះឆ្លើយថា“តាមតែកូនគិតចុះ ចំណែកខាងម្តាយនិងឪពុករកស៊ីគ្រាន់តែមាត់ ហើយនិងថែរក្សាទ្រព្យទុកអោយកូន ចូរកូនគិតរកអម្រស់អម្រេបរខ្លួនឯងចុះ”។ អាឡេវនៅនិងម្តាយឪពុកបានពីរបីថ្ងៃក៏លាចេញដំណើរទៅទៀត លុះទៅដល់ស្រុកធំវាចូលទៅមើលក្នុងវាំងសព្វគ្រប់ហើយចេញមករកមើលផ្ទះនាហ្មឺនសេដ្ឋី ក៏ឃើញសេដ្ឋីម្នាក់មានផ្ទះធំទ្រនំខ្ពស់មានទ្រព្យសម្បត្តិច្រើន មានរោងរទេះគោក្របីដំរីសេះ មនុស្សម្នាខ្ញុំកំដរពាសពេញមានច្បារដំណាំជាឧទ្យាន មានដើងផ្កាគ្រប់ជំពូកគ្រប់ពណ៌ដាក់ហែជាជួរក្នុងសួនច្បារមានត្រីប្រាក់ត្រីមាសមានស្រះដាំដើមឈូកសឈូកក្រហមព្រលិតរំចង់ស្បង់ជុះពាសពេញ ហើយមានកូនក្រមុំមិនទាន់មានប្តី។ អាឡេវមានចិត្តស្រឡាញ់ចង់បាន ក៏ឋូលទៅផ្ទះសេដ្ឋីហើយជំរាបសុំខ្លួននៅធ្វើជាកូនក្មួយ។ សេដ្ឋីឃើញអាឡេវមកសុំខ្លួននៅធ្វើជាកូនក្មួយដូច្នេះ ក៏មានចិត្តអាណិតស្រឡាញ់ ហើយសួរថា“ឯងនៅស្រុកណា ?ម្តាយឪពុកនៅស្រុកណា ?”។ អាឡេវជំរាបសេដ្ឋីថា“ខ្ញុំបាទនៅស្រុកឆ្ងាយណាស់ ឪពុកម្តាយខ្ញុំបាទមានទ្រព្យរបស់ខ្ញុំកំដរគោក្របីដំរីសេះផ្ទះសំម្បែងដូចលោកដែរ ប៉ុន្តែគាត់មានជំងឺឈឺស្លាប់អស់ហើយ ខ្ញុំបាទតូចចិត្តណាស់មិនចង់នៅត្បិតធ្លាប់មានម៉ែឪ ឥឡូវនេះនៅតែម្នាក់ឯងបានជាខ្ញុំបាទចោលផ្ទះសម្បែងទ្រព្យរបស់មកសុំនៅជាមួយនឹងលោកតាមតែលោកប្រើធ្វើការងារអ្វីៗខ្ញុំបាទទទួលទាំងអស់”។ សេដ្ឋីក៏ព្រមទទួលយកអាឡេវអោយនៅ ចាប់ដើមតាំងពីថ្ងៃមកនៅនឹងសេដ្ឋីអាឡេវតែងភ្ញាក់អំពីព្រឹកបោសផ្ទះ ថែទាំរបស់ទ្រព្យរៀបទុកដាក់តាមទីកន្លែង ហើយខំធ្វើការដូចជារបស់ខ្លួន។ សេដ្ឋីឃើញអាឡេវឧស្សាហ៍ធ្វើការថែទាំរបស់ទ្រព្យមិនមានអោយឈ្មើសចិត្ត ក៏រឹតតែស្រឡាញ់ឡើងអោយអាឡេវត្រួតត្រាដាស់តឿនមនុស្សម្នាខ្ញុំកំដរទាំងអស់។ រាល់តែវេលាសេដ្ឋីទៅគាល់ស្តេចបានយកអាឡេវទៅផង លុះទៅជាញឹកញយអាឡេវស្គាល់ពួកក្រមការ និងកូនក្មួយទាំងអស់ តមកទៀតវាស្គាល់ដល់នាហ្មឺនធំតូច តាំងពីលោកក្រឡាហោម យមរាជ ចក្រវាំងនិងនាហ្មឺនធំតូចឯទៀត ប៉ុន្តែអាឡេវធ្វើចិត្តជាទុកជានរណាត្មះដៀលដូចម្តេច ក៏មិនចេះខឹងនឹងគេសូម្បីកូនក្មួយផងគ្នាធ្វើដូចម្តេចៗក្តី អាឡេវក៏មិនចេះតបមិនចេះខឹងឡើយ កាលណា

អាឡេវតាមសេដ្ឋីទៅគាល់ស្តេច ហើយមានគេសួរថា "ឈ្មោះអី ?" អាឡេវប្រាប់ថាខ្ញុំឈ្មោះថាអាឡេវតេវ ។ ពួកនាហ្មឺនតែឃើញអាឡេវទៅហើយក៏ហៅថាអាឡេវតេវដូច្នេះ ឯង ។ វេលាក្រោយមក អាឡេវទៅលេងនៅសាលាជំនុំស្តាប់ចៅក្រមជំនុំជំរះក្តីតែសព្វថ្ងៃ ក៏ចេះច្បាប់ទំលាប់ច្រើន ហើយវារើសកាកសំបុត្រដែលគេបោះចោលមានទាំងស្នាមត្រានៅបោះនៅនោះផង តាំងពីត្រាលោកក្រឡាហោម យមរាជ និងនាហ្មឺនធំតូចទាំងអស់ ដែលមានមាសប្រាក់ច្រើន ហើយវាយកក្រមួនមកសូនធ្វើជាត្រាវាស់នឹងត្រាកាកសំបុត្រចាស់ ហើយឆ្លាក់អោយត្រូវតាមត្រាចាស់ រួចវាធ្វើជាសំបុត្រសឹងមានឈ្មោះនាហ្មឺនអស់នោះជំពាក់ប្រាក់ខ្លះ១០០ណែន ខ្លះ២០០ណែន ខ្លះ៥០០ណែនគ្រប់តែនាហ្មឺនធំតូចទាំងអស់ហើយបត់ទុកក្នុងហឹបមួយពេញ បើខ្លួនវាមិននៅ ទៅធ្វើការទីណាក្តី វាយកហឹបនោះទៅផ្ញើនឹងប្រពន្ធសេដ្ឋី ហើយផ្តាំថា "កុំអោយនរណាបើកអោយសោះ" ដល់វាវិលមកក៏ទៅយកហឹបនោះមកវិញធ្វើដូច្នេះជារឿយៗ ។

លុះដល់ថ្ងៃក្រោយទៀតអាឡេវរៀបទៅធ្វើការក៏យកហឹបទៅផ្ញើនឹងប្រពន្ធសេដ្ឋីហើយផ្តាំថា "អ្នកប្រយ័ត្នរក្សាទុកអោយល្អកុំអោយនរណាបើកមើលលេង" ។ ឯប្រពន្ធសេដ្ឋីនឹកឆ្ងល់នឹងហឹបអាឡេវណាស់ ក៏បើកមើលឃើញសំបុត្រពេញក្នុងហឹប ហើយលាមើលសំបុត្រអស់នោះបានឃើញសេចក្តីក្នុងសំបុត្រថា "ពួកនាហ្មឺនជំពាក់ប្រាក់សឹងមានចំនួនគ្រប់គ្នាទាំងអស់" ហើយបោះត្រាផង ។ លុះរើសមើលសំបុត្រទាំងអស់ឃើញសុទ្ធតែនាហ្មឺនជំពាក់ប្រាក់ជាច្រើនណាស់ដូច្នេះក៏យកហឹបសំបុត្រនោះទៅបង្ហាញសេដ្ឋីជាប្តី ។ ឯសេដ្ឋីបានឃើញសំបុត្រអាឡេវសព្វគ្រប់ហើយ ក៏និយាយនិងប្រពន្ធថាកាលអាឡេវវាមកនៅនិងយើងនោះអញបានសួរវាពីម្តាយឪពុកនៅឯណាវាប្រាប់ថាគ្មានម្តាយឪពុកទេស្លាប់អស់ហើយៗ វាប្រាប់អញថាកាលដែលម្តាយឪពុកវានៅរស់នៅឡើយនោះ វាមានទ្រព្យសម្បត្តិដូចជាយើងនេះដែរ ឥឡូវនេះមកឃើញសំបុត្រអស់នាហ្មឺនជំពាក់ប្រាក់វាច្រើនម្ល៉េះ នេះសឹងត្រូវនឹងពាក្យវានិយាយពីមុននោះប្រាកដមែនគំនិតប្រាជ្ញាវាជាមនុស្សមានពូជ មួយទៀតការងារទាំងអស់ក្នុងផ្ទះយើងសព្វថ្ងៃនេះ ក៏



បានវាជួយជាស់តឿនថែទាំមើលរក្សាដឹងបាត់ដឹងគង់ដឹងខូចដឹងជា មានតែវានឹងហើយទុកជាកូន ឥឡូវកូនស្រីយើងមួយនេះពេញក្រមុំល្មមមានប្តីហើយ ពួកស្តេចនាហ្មឺនមកដណ្តឹងចង់បានជាច្រើនណាស់ ហើយយើងមិនត្រូវចិត្តបានជាយើងមិនអោយឥឡូវនេះបើយើងអោយទៅអាឡេវនោះ យើងខ្មាសគេណាស់ត្បិតវាជាមនុស្សកំព្រាក្បាលមួយមកនៅស្រុកអាយ គ្មាននរណាស្គាល់ពូជពង្សវង្សា ជាល្អអាក្រក់ បើយើងមិនអោយកូនយើងជាប្រពន្ធវា ដូចជានឹកស្តាយ ត្បិតគំនិតមាយាទវាជាល្អហើយជួយឈឺឆ្អាលក្នុងការងារយើងដូចជាការងាររបស់ខ្លួនវាដែរ ដំណើរនេះក្រមើគិតណាស់ ។ ឯប្រពន្ធសេដ្ឋីឆ្លើយថាត្រង់កិច្ចការដែលធ្វើមិនអោយខ្មាសគេនោះវាងាយទេយើងនឹងរៀបការក្នុងវេលាយប់ហើយរៀបបន្តិចបន្តួចសោះតែខានកុំអោយខ្មោចព្រៃខឹង យើងផ្សំផ្គុំជាប្រពន្ធគ្នាទៅ បើយូរទៅហើយគេដឹង នោះយើងក៏អស់ខ្មាសគេហើយពីព្រោះវាមានបំណុលក៏ច្រើនហើយដែរ ។ ហេតុតែព្រេងសំណាងរបស់អាឡេវ និងកូនក្រមុំសេដ្ឋីនោះ ត្រូវបានគ្នាជាប្តីប្រពន្ធ សេដ្ឋីគិតឃើញព្រមដូចពាក្យប្រពន្ធពន្យល់ក៏ព្រមអោយកូនក្រមុំជាប្រពន្ធអាឡេវ ហើយហៅអាឡេវមកប្រាប់ថា "តាំងពីថ្ងៃដែលឯងមកនៅនឹងអញៗមើលទៅគំនិតមាយាទចិត្តថ្លើមឯងឈឺឆ្អាលក្នុងការងារអញដូចជាកូនបង្កើតបើដូច្នេះអញអោយកូនក្រមុំជាប្រពន្ធឯង" ។ ឯអាឡេវឮសេដ្ឋីប្រាប់ថាកូនក្រមុំជាប្រពន្ធដូច្នេះ ក៏មានចិត្តត្រេកអរណាស់ សេដ្ឋីហៅកូនក្រមុំរៀបសំពះមេបាចាស់ទុំរៀបសែនព្រេនតាមសណ្តាប់បុរាណជាប្តីប្រពន្ធទៅ ។

លុះការរួចពីរបីថ្ងៃប្រពន្ធអាឡេវគិតទៅគាល់ស្តេចក្នុងវាំងបាននិយាយប្រាប់អាឡេវជាប្តី ។ ឯអាឡេវក៏និយាយផ្តាំប្រពន្ធថា "បងទៅចាំនៅសាលាជំនុំបើនាងឃើញបងបោយដៃហៅ ត្រូវនាងលើកជើងពានស្លាមកលុតជង្គង់ហុចស្លាពាននោះអោយបងបងទទួលយកហើយនាងសំពះទៅវិញចុះ" ។ លុះនិយាយផ្តាំប្រពន្ធសព្វគ្រប់ហើយអាឡេវក៏ស្លៀកសំពត់ចាស់ពាក់អាវដូចកាលធ្វើការពីមុន ហើយអង្គុយលេងនៅសាលាជំនុំ ។ ពួកនាហ្មឺនសព្វមុខមន្ត្រីចៅក្រមសាលាភ្នាក់ងារក្រមការ ឃុនហ្មឺនមហាតឡិកមក

ពាសពេញ ឃើញអាឡេវអង្គុយនៅសាលានាហ្មឺនខ្លះត្បកក្បាល ខ្លះកេះខ្នងទាញដៃ ខ្លះអោយអាឡេវឡើងធ្វើត្លុកក្រមាច់លេង ត្បិតធ្លាប់លេងពីមុនមកដូច្នេះឯង ។ ឯអាឡេវជាមនុស្សមានប្រាជ្ញាចេះក្រមាច់កំប្លែងលេងអោយគេចូលចិត្តមិនចេះខឹងនឹងនរណាទេ ទោះនាហ្មឺនសព្វមុខមន្ត្រីឃុនហ្មឺនមហាតឡឹកនូវក្រុមការភ្នាក់ងារប្រើវាដូចម្ដេចក្ដី លេងដូចម្ដេចក្ដី ក៏មិនចេះខឹងមិនចេះប្រកែកអោយអ្នកណាអាក់អន់ចិត្តតាំងតែពីដើមមកដូច្នេះឯង ហើយពួកនាហ្មឺនមិនដឹងជាអាឡេវបានកូនក្រមុំសេដ្ឋីមកធ្វើជាប្រពន្ធផង ស្មានថាអាឡេវជាមនុស្សផ្ដេសផ្ដាសដើរសុំទានគេស៊ីរកទីលំនៅគ្មានបានជានាំគ្នាមាក់ងាយវា ។ លុះដល់កូនសេដ្ឋីជាប្រពន្ធអាឡេវជិះអង្រឹងស្នែង ហើយមានមនុស្សម្នាខ្ញុំកំដរកាន់ប្រអប់មាសប្រាក់ដើរពេញពាសផ្លូវមក នាហ្មឺនទាំងអស់ក៏និយាយថា “ហ្ន៎! មើលកូនសេដ្ឋីល្អណាស់ដើរចូលក្នុងវាំង” នាហ្មឺនខ្លះលាន់មាត់ថា “ល្អមែន កូនស្ដេចកូននាហ្មឺនដណ្ដឹងជាច្រើនហើយ តែមិនបាន” ។ ឯអាឡេវឮនាហ្មឺននិយាយគ្នាថា កូនស្ដេចនាហ្មឺនដណ្ដឹងកូនក្រមុំសេដ្ឋីមិនព្រមអោយដូច្នោះ ក៏ឆ្លើយឡើងថា “បើអស់លោកថាដណ្ដឹងកូនក្រមុំសេដ្ឋីអោយកូនលោកមិនបាន លោកចាំមើលខ្ញុំបាទវិញចុះ វេលាកូនក្រមុំសេដ្ឋីចេញមកអំពីវាំង ខ្ញុំបាទនឹងហៅអោយចូលមកហើយអោយយកស្លា មកអោយខ្ញុំបាទទទួលទាន លោកហ៊ានភ្នាល់ទេ ?” ពួកនាហ្មឺនឮអាឡេវថាដូច្នេះមិនជឿ ត្បិតមិនដឹងជាសេដ្ឋីអោយកូនក្រមុំទៅជាប្រពន្ធអាឡេវសោះ មួយទៀតមិនដឹងថាអាឡេវវាក្រមាច់លេងផ្ដេសផ្ដាស តែដោយផ្ទុះនាហ្មឺនវេលាទៅផ្ទះវិញមិនបានលេងផ្ដេសផ្ដាសទេ បានជាមាក់ងាយវាខ្លាំងណាស់ ហើយមិនដឹងជាអាឡេវមានប្រាជ្ញាច្រើនដល់ម្លឹងសោះ ទើបនាំគ្នានិយាយភ្នាល់នឹងវាថា “បើឯងហៅកូនក្រមុំសេដ្ឋីចូលមកយកស្លា មួអោយឯងស៊ីបានអញហ៊ានភ្នាល់នឹងឯង ប៉ុន្តែឯងគ្មានអ្វីដាក់ភ្នាល់នឹងអញទេ” ។ អាឡេវឮពួកនាហ្មឺនថាដូច្នេះក៏ឆ្លើយឡើងថា “លោកកុំព្រួយប្រសាសន៍នឹងខ្ញុំបាទ បើខ្ញុំបាទចាញ់លោក ខ្ញុំបានធ្វើសំបុត្រនៅបំរើជាខ្ញុំលោកដល់អស់មួយជីវិត តាមចិត្តលោកប្រើធ្វើអ្វីខ្ញុំបាទទទួលធ្វើទាំងអស់” ។ នាហ្មឺនសព្វមុខមន្ត្រីទាំងអស់ឮអាឡេវថាដូច្នេះ



ក៏អរគ្រប់គ្នាដោយចង់បានអាឡេវមកធ្វើជាខ្ញុំ ត្បិតវាចេះនិយាយភូតភរ ក្រមាច់កំប្លែងលេងគ្រាន់សប្បាយ ដោយសារវាមួយទៀតមាក់ងាយវាថាជាមនុស្សចោលម្សៀត ធ្វើម្ដេចនឹងហៅកូនក្រមុំសេដ្ឋីអោយចូលមកបានហើយនិយាយគ្នាថា “យើងយកអាឡេវធ្វើជាខ្ញុំ គ្រាន់និយាយភូតភរក្រមាច់លេង ហើយយើងចែកគ្នាប្រើលេងសប្បាយ បើវាចង់បានរបស់ទ្រព្យប្រាក់មាសប៉ុន្មាន យើងអោយវាដាក់ក្នុងសំបុត្រភ្នាល់គ្នាតាមចិត្តវាចុះ ត្បិតវាមុខជាចាញ់យើងហើយ” ។ អាឡេវនឹងពួកនាហ្មឺនធ្វើសំបុត្របង្កាន់ដៃភ្នាល់ តាមដំណើរសព្វគ្រប់ហើយ ទើបពួកនាហ្មឺនប្រាប់អាឡេវថា “ឯងចង់បានមាសប្រាក់ប៉ុន្មាន? ដំរីចងកូបសេះចងអានទាំងគ្រឿងដែលជិះមកទាំងប៉ុន្មាន ចូរដាក់ក្នុងសំបុត្រតាមចិត្តឯងចុះ” ។ អាឡេវក៏សរសេរដាក់ក្នុងបង្កាន់ដៃដែលភ្នាល់គ្នាអោយតែច្រើន ទាំងមាសទាំងប្រាក់ ទាំងដំរីទាំងសេះគ្រប់គ្រឿងហើយ ជូនទៅពួកនាហ្មឺនអោយបោះត្រា រួចទទួលយកមកវេចមួយសម្ពាយក្រវាត់ទុក ហើយទៅអង្គុយចាំនៅមាត់ទ្វារសាលាបន្តិច ឃើញកូនសេដ្ឋីជាប្រពន្ធវាចេញពីក្នុងវាំង វាក៏បោយដៃហៅថា “នាងយកស្លាមកអោយបងស៊ី” ។ កូនសេដ្ឋីឮប្ដីហៅអោយយកស្លាមកដូច្នេះ ក៏ម្នីម្នាចុះពីអង្រឹងស្នែង ហើយដាក់ស្លាលើជើងពានយកមកអោយប្ដី ។ អាឡេវ ក៏ទទួលយកស្លាស៊ីហើយនាំប្រពន្ធនិងខ្ញុំកំដរឡើងជិះសេះដំរី ដែលតែងគ្រឿងគ្រប់ស្រាប់ទៅកាន់ផ្ទះសេដ្ឋីជាឪពុកក្មេក អាឡេវនិយាយផ្ដាំថា “បើលោកឪពុកលោកម្ដាយ ឬអ្នកឯណាជាមនុស្សនៅក្នុងផ្ទះក្ដី ក្រៅផ្ទះក្ដី ឬអ្នកជិតខាងក្ដីគេសួរថាបានសេះដំរីពីណាមក ?អោយជំរាបអោយប្រាប់ថា ទារបំណុលអំពីគេ” ។ ឯពួកនាហ្មឺនសព្វមុខមន្ត្រីក្រុមការភ្នាក់ងារនូវឃុនមហាតឡឹក ដែលភ្នាល់ចាញ់អាឡេវ ស្រាប់តែភ័យភ្ញែកសរៀងខ្លួនស្ដាយរបស់ទ្រព្យនិងដំរីសេះជាជំនិះធ្លាប់ជិះជាលម្អ ត្រូវចិត្តសុខ្ខសឹងតែគ្រឿងមាសនិងប្រាក់ពន់ពេក ហើយនិយាយគ្នាថា “យើងបង់គំនិតនឹងអាឡេវហើយជាន់នេះ” ឯអាឡេវនិងប្រពន្ធខ្ញុំកំដរជិះដំរីសេះមានកូបមានអាន នូវគ្រឿងប្រដាប់សុខ្ខសឹងតែមាស និងប្រាក់ លុះទៅដល់ផ្ទះហើយ សេដ្ឋីជាឪពុកក្មេកម្ដាយក្មេកនូវអស់មនុស្សម្នាភ្នាក់ងារក្នុងផ្ទះ ឃើញដំរី

សេះពាសពេញដូច្នោះ ក៏នឹកឆ្ងល់ ហើយសេដ្ឋីប្រើមនុស្សអោយទៅសួរអាឡេវៗក៏ប្រាប់ថា"ទារបំណុលអំពីគេមក" ។ សេដ្ឋីជាឪពុកក្មេកម្តាយក្មេកក៏អរនិយាយគ្នាថា"យើងអស់ខ្មាសគេហើយ" ។ ចាប់ដើមអំពីថ្ងៃនោះមកសេដ្ឋីប្តីប្រពន្ធក៏រឹតតែស្រឡាញ់អាឡេវលើសពីមុនទៀត ។ អាឡេវក៏ទៅទារប្រាក់ពីពួកនាហ្មឺនសព្វមុខមន្ត្រីតែសព្វថ្ងៃ ជញ្ជូនយកមកហើយវាគិតធ្វើការរកស៊ីជួសសេដ្ឋីជាឪពុកក្មេកម្តាយក្មេក មិនអោយព្រួយចិត្តគ្រប់ជំពូក ។ នៅយូរមកសេដ្ឋីចាស់ជរាអស់អាយុទៅ អាឡេវក៏បានជាសេដ្ឋីធំក្នុងនគរនោះឯង ។

## ត្រុកៗអ្នកស្រុកមើលចាយ

## រលាយគ្មនខ្វាយ មានខ្ជះមានតំណ